**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**លេខៈ មព ០៩/២០២៥ កបផ.សអ**

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងកិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ

តបតាមការអញ្ជើញរបស់ ឯកឧត្តម ដាតុ សេរី យូតាមា ហាជី មហាម៉ាដ ប៊ីន ហាជី ហាហ្សាន រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (AICHR) និងកិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៥ ។

**ជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស**

កិច្ចប្រជុំបានកត់សម្គាល់លើរបាយការណ៍ប្រចាំឆ្នាំ២០២៥ (ពីខែកក្កដា ឆ្នាំ២០២៤ ដល់ខែមិថុនា ឆ្នាំ២០២៥) របស់ AICHR និងបានឯកភាពលើកម្មវិធី/សកម្មភាពអាទិភាពរបស់ AICHR សម្រាប់ឆ្នាំ២០២៦។ កិច្ចប្រជុំទន្ទឹងរង់ចាំការឯកភាពលើផែនការសកម្មភាពរយៈពេល៥ឆ្នាំ របស់ AICHR (២០២៦-២០៣០) នៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៨ នាពេលខាងមុខ ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសសមាជិកអាស៊ានបន្ថែមទៀត ដើម្បីពង្រឹងការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្សនៅក្នុងតំបន់។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរចំពោះវឌ្ឍនភាពប្រកបដោយស្ថិរភាព និងអត្ថន័យ ដែលសម្រេចបានដោយ AICHR ក្នុងការបញ្ជ្រាបសិទ្ធិមនុស្សនៅក្នុងសសរស្តម្ភសហគមន៍អាស៊ានទាំងបី ដែលបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងអាស៊ានប្រកបដោយបរិយាប័ន្ន យុត្តិធម៌ និងផ្តោតលើប្រជាជន។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី លើកទឹកចិត្ត AICHR ឱ្យកសាងភាពជា

ដៃគូបន្ថែមទៀតជាមួយដៃគូសន្ទនាអាស៊ាន ស្ថាប័នតាមវិស័យអាស៊ាន សង្គមស៊ីវិល និងស្ថាប័នអន្តរជាតិនានា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកទឹកចិត្ត AICHR ឱ្យបង្កើនសន្ទុះវិជ្ជមាននិងពង្រឹងការងាររបស់ខ្លួនបន្ថែមទៀតតាមរយៈផែនការការងាររយៈពេលប្រាំឆ្នាំ (២០២៦-២០៣០) ដែលផ្តល់កាលានុវត្តភាពឱ្យ AICHR ប្រមូលសរុបសមិទ្ធផលកន្លងមក ដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន ព្រមទាំងកំណត់គោលដៅរបស់ខ្លួនឱ្យស្របនឹងអាទិភាពក្នុងតំបន់កាន់តែទូលំទូលាយ ស្របតាមចក្ខុវិស័យអាស៊ាន ឆ្នាំ២០៤៥ ដើម្បីសម្រេចបាននូវគោលដៅរួម និងពង្រឹងកេរ្តិ៍ឈ្មោះអាស៊ានក្នុងនាមជាសហគមន៍ដែលប្តេជ្ញាការពារសេចក្តីថ្លៃថ្នូរ និងការលើកកម្ពស់សិទ្ធិមនុស្សជាសកល។

**<u>កិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ</u>**

កិច្ចប្រជុំបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តរបស់អាស៊ាន ក្នុងការរក្សាអាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងអាវុធប្រល័យពូជសាសន៍ផ្សេងទៀត អនុលោមតាមធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញា SEANWFZ ។ នៅក្នុងការខិតខំប្រឹងប្រែងនេះ កិច្ចប្រជុំបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអនុវត្តសន្ធិសញ្ញានេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព តាមរយៈផែនការសកម្មភាពឆ្នាំ២០២៣-២០២៧។ កិច្ចប្រជុំក៏បានស្វាគមន៍វឌ្ឍនភាពដែលកំពុងបន្តចំពោះសេចក្តីសម្រេចរយៈពេលពីរឆ្នាំស្តីពីសន្ធិសញ្ញា SEANWFZ នៅសម័យប្រជុំលើកទី៨០ ស្តីពីមហាសន្និបាតអង្គការសហប្រជាជាតិ ហើយបានសង្កត់ធ្ងន់លើតម្រូវការដើម្បីរក្សានូវសន្ទុះជាវិជ្ជមាននេះ ក្នុងការលើកកម្ពស់សន្ធិសញ្ញាជាអន្តរជាតិ។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់កាន់តែខ្លាំងឡើងនៃសន្ធិសញ្ញា SEANWFZ ក្នុងបរិបទនៃទិដ្ឋភាពភូមិសាស្ត្រនយោបាយសកលនាពេលបច្ចុប្បន្ន និងការកើនឡើងនៃបញ្ហាប្រឈមចំពោះតំបន់មិនរីកសាយអាវុធនុយក្លេអ៊ែរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញនូវការអំពាវនាវរួមគ្នារបស់អាស៊ានសម្រាប់រដ្ឋអាវុធនុយក្លេអ៊ែរ (NWS) ឱ្យទទួលស្គាល់ជាផ្លូវការនូវសន្ធិសញ្ញា SEANWFZ ដោយក្នុងន័យនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះការត្រៀមខ្លួនរបស់ប្រទេសចិនក្នុងការចុះហត្ថលេខាលើពិធីសារដោយគ្មាន "ឧបម្រុង" និងបានកោតសរសើរចំពោះវឌ្ឍនភាពឆ្ពោះទៅការចូលជាសមាជិកនៃសន្ធិសញ្ញានេះ របស់ទីម័រឡេស្តេនាអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ នៅខែតុលា ឆ្នាំ២០២៥។

**<u>កិច្ចប្រជុំទ្វេភាគី ក្នុងឱកាសកិច្ចប្រជុំខាងលើ៖</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងលោកជំទាវ Ma. Theresa P. Lazaro រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋហ្វីលីពីន បានពិភាក្សាពីការត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជានាពេលខាងមុខ របស់**ឯកឧត្តម** Ferdinand R. Marcos Jr. ប្រធានាធិបតីហ្វីលីពីន ដោយបានគូសបញ្ជាក់ពីសារៈសំខាន់នៃដំណើរទស្សនកិច្ចនេះ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងលោកជំទាវ Lazaro ក៏បាន

ជជែកគ្នាអំពីការធ្វើឱ្យកាន់តែស៊ីជម្រៅ និងការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ព្រមទាំងបានផ្លាស់ប្តូរយោបល់គ្នាលើកិច្ចសហប្រតិបត្តិការក្នុងតំបន់ដែលជាផលប្រយោជន៍រួម។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តម BUI Thanh Son ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើននៃកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ជាញឹកញាប់រវាងប្រទេសទាំងពីរ។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានផ្លាស់ប្តូរយោបល់គ្នាលើវិស័យសំខាន់ៗនៃកិច្ចសហប្រតិបត្តិការ រួមមានការវិនិយោគ ទេសចរណ៍ ការផ្លាស់ប្តូរប្រជាជននិងប្រជាជន និងការតភ្ជាប់។ ភាគីទាំងពីរក៏បានពិភាក្សាពីការត្រៀមរៀបចំកិច្ចប្រជុំលើកទី២១ នៃគណៈកម្មការចម្រុះរវាងកម្ពុជា និងវៀតណាម ដែលនឹងប្រព្រឹត្តិទៅនៅក្នុងឆ្នាំនេះ នៅកម្ពុជា៕

ថ្ងៃពុធ ១៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥